# ផែនការអភិរក្ស និងគ្រប់គ្រង

## គោលបំណង ១. កាត់បន្ថយបុព្វហេតុដែលបង្កដោយផ្ទាល់ ឬដោយប្រយោលដល់ការបាត់បង់អណ្តើកសមុទ្រ

| កម្មវិធី | សកម្មភាព | អាទិភាព | ស្ថានភាពនៃការអនុវត្តន៍ |
|---|---|---|---|
| 1.1 ធ្វើអត្តសញ្ញាណ និងចងក្រងឯកសារអំពីការគំរាមកំហែងចំពោះអណ្តើកសមុទ្រ និងទីជំរករបស់វា | ក) ចងក្រង និងរៀបចំទិន្នន័យដែលមានបច្ចុប្បន្នអំពីការគំរាមកំហែងចំពោះអណ្តើកសមុទ្រ<br>ខ) បង្កើតកម្មវិធីប្រមូលទិន្នន័យគោល និងសិក្សាតាមដាន ដើម្បីប្រមូលផ្តុំពិតមានស្តីពីប្រភេទ និងវិសាលភាពនៃការគំរាមកំហែង<br>គ) កំនត់បណ្តាភាវៈដែលរងឥទ្ធិពលពីការប្រមូលផលតាមបែបបុរាណ និងដោយផ្ទាល់ ការនេសាទបានដោយចៃដន្យ និងប្រភពផ្សេងទៀតដែលនាំឱ្យអណ្តើកបាត់បង់ | | |
| 1.2 កំនត់ និងចាត់វិធានការណ៍សមស្របបំផុត ដើម្បីកាត់បន្ថយការគំរាមកំហែងទាំងនោះ ចំពោះបណ្តាភាវៈអណ្តើកសមុទ្រ និងទីជំរករបស់វា | ក) ធ្វើអត្តសញ្ញាណ និងចងក្រងឯកសារអំពីវិធានការណ៍សមស្របបំផុតសំរាប់អភិរក្ស និងគ្រប់គ្រងបណ្តាភាវៈអណ្តើកសមុទ្រក្នុងតំបន់<br>ខ) កែសំរួល និងបន្សាំវិធីនៃការអភិរក្ស និងគ្រប់គ្រងដែលសមស្របបំផុតសំរាប់បណ្តាភាវៈអណ្តើកសសមុទ្រ | | |
| 1.3 អនុវត្តកម្មវិធីដើម្បីកែតំរូវ យន្តការសេដ្ឋកិច្ចដែលអាចបង្កជាការគំរាម-កំហែងចំពោះបណ្តាភាវៈអណ្តើកសមុទ្រ | ក) ធ្វើការសិក្សាសេដ្ឋកិច្ចសង្គមក្នុងចំណោមសហគមន៍ដែលមានអន្តរកម្មជាមួយអណ្តើកសមុទ្រ និងទីជំរករបស់វា<br>ខ) ធ្វើអត្តសញ្ញាណរាល់កំណែប្រែដែលចង់បានចំពោះវិធានការណ៍សេដ្ឋកិច្ច ដើម្បីកាត់បន្ថយការគំរាមកំហែង និងការបាត់បង់ និងបង្កើតកម្មវិធីដើម្បីអនុវត្តកំណែប្រែទាំងនោះ<br>គ) ធ្វើអត្តសញ្ញាណធនធាន និងប្រភពផ្តល់មូលនិធិសំរាប់កម្មវិធីទាំងនោះ | | |
| កាត់បន្ថយជាអតិបរមានូវ ឱកាសនៃការប្រមូលផលដោយអចេតនា និងការបាត់បង់អណ្តើកសមុទ្រដោយសារសកម្មភាពនេសាទ | ក) បង្កើត និងប្រើប្រាស់ឧបករណ៍ យន្តបករណ៍ និងបច្ចេកទេសដើម្បីកាត់បន្ថយការនេសាទអណ្តើកដោយចៃដន្យ ដូចជាបករណ៍ដែលអាចឱ្យអណ្តើកសមុទ្រគេចចេញរួច និងការកំនត់ពេលបិទនេសាទនៅតាមតំបន់ ឬតាមពេលវេលា<br>ខ) រៀបចំនីតិវិធី និងកម្មវិធីបណ្តុះបណ្តាលដើម្បីជំរុញអនុវត្តវិធានការណ៍ទាំងនេះ ដូចជាប្រព័ន្ធតាមដាននាវា និងអធិការកិច្ចក្នុងសមុទ្រនៅតាមផែនេសាទ និងកម្មវិធីសង្កេតការណ៍លើនាវា<br>គ) ការផ្លាស់ប្តូរពិតមាន និងផ្តល់ជំនួយបច្ចេកទេសដល់បណ្តារដ្ឋជាហត្ថលេខីតាមការស្នើសុំ ដើម្បីជំរុញសកម្មភាពទាំងនេះ<br>ឃ) ទាក់ទង និងសំរបសំរួលជាមួយអង្គការឧស្សាហកម្ម និងគ្រប់គ្រងការនេសាទ ដើម្បីបង្កើត និងអនុវត្តយន្តការកាត់បន្ថយការនេសាទអណ្តើកដោយចៃដន្យ នៅក្នុងដែនសមុទ្រជាតិ និងនៅសមុទ្រអន្តរជាតិ | | |

| | | | |
|---|---|---|---|
| | ង) គាំទ្រសេចក្តីសំរេចលេខ ៤៦/២១៥នៃកិច្ចប្រជុំសហប្រជាជាតិ ពាក់ព័ន្ធនឹងការផ្អាកប្រើប្រាស់អួនបណ្តែតទ្រង់ទ្រាយធំនៅសមុទ្រអន្តរជាតិ<br>ច) បង្កើត និងអនុវត្តកម្មវិធីរក្សាទុក និងប្រើអួនឡើងវិញ ដើម្បីកាត់បន្ថយការចោលសំណល់ឧបករណ៍នេសាទនៅសមុទ្រ និងតាមឆ្នេរសមុទ្រ<br>ឆ) ផ្តល់ និងធានាថាមានការប្រើប្រាស់សម្បទានៅតាមផែសំរាប់ទុកដាក់សំណល់ពីនាវាសមុទ្រ | | |
| ហាមឃាត់ការប្រមូលផលដោយផ្ទាល់ (ចាប់ ឬសំលាប់) និងពាណិជ្ជកម្មក្នុងប្រទេសនូវ អណ្តើកសមុទ្រ ស៊ុតរបស់វា ចំណែកនៃសារពាង្គកាយ ឬផលិតផលពីអណ្តើក តែមានការលើកលែងចំពោះការប្រមូលផលតាមបែបបុរាណដោយសហគមន៍មូលដ្ឋាន នៅក្នុងដែនយុត្តា-ធិការរៀង១ខ្លួន ក្នុងករណីដែល ការប្រ-មូលផលបែបនោះពុំបង្កមហន្តរាយដល់កិច្ចប្រឹងប្រែងការពារ អភិរក្ស និង ស្តារបណ្តាភាវៈអណ្តើកសមុទ្រ និងទីជំរករបស់វា ហើយបណ្តាភាវៈនៃអណ្តើកសមុទ្រប្រភេទ ទាំងនោះអាចធានាអត្ថិភាពរបស់ខ្លួនសំរាប់ការប្រមូលផល | ក) ក្នុងករណីមិនទាន់មាននៅឡើយ អនុម័តច្បាប់ហាមឃាត់ការប្រមូលផលដោយផ្ទាល់ រួមទាំងការធ្វើពាណិជ្ជកម្មក្នុងស្រុក<br>ខ) វាយតំលៃពីកំរិត និងផលប៉ះពាល់ពីការប្រមូលផល តាមបែបបុរាណនូវអណ្តើកសមុទ្រ និងស៊ុតរបស់វា<br>គ) បង្កើតកម្មវិធីគ្រប់គ្រងដែលអាចរួមបញ្ចូលការដាក់កំហិតពីកំរិតប្រមូលផលជាអន្តរជាតិ<br>ឃ) កំនត់តំលៃខាងផ្នែកវប្បធម៌ និងប្រពៃណី និងការប្រើប្រាស់សេដ្ឋកិច្ចនៃអណ្តើកសមុទ្រ (រួមទាំងតំលៃដែលអាចប្រើប្រាស់បាន និងដែលមិនអាចប្រើប្រាស់បាន)<br>ង) ក្នុងករណីសមស្រប ចរចាអំពីកិច្ចព្រមព្រៀងគ្រប់គ្រងស្តីពីកំរិតនិរន្តភាពនៃការប្រមូលផលតាមបែបបុរាណ ដោយពិគ្រោះយោបល់ជាមួយបណ្តារដ្ឋពាក់ព័ន្ធ ដើម្បីធានាថាការប្រមូលផលបែបនោះមិនបង្កមហន្តរាយដល់កិច្ចប្រឹងប្រែងអភិរក្ស | | |
| បង្កើតកម្មវិធីគ្រប់គ្រងឆ្នេរសមុទ្រសំរាប់ អណ្តើកពង ដើម្បីបង្កើនចំនួនកូនអណ្តើក ក្នុងធម្មជាតិ | ក) វាយតំលៃប្រសិទ្ធិភាពនៃកម្មវិធីគ្រប់គ្រងសំបុក និងឆ្នេរ<br>ខ) កាត់បន្ថយអត្រាស្លាប់នៃស៊ុត និងកូនញាស់ ដើម្បីបង្កើតចំនួនកូនញាស់ និងអត្រាគង់វង់ និងក្នុងករណីអាចធ្វើបានគួរប្រើប្រាស់បច្ចេកទេសអភិរក្សដែល យកចិត្តទុកដាក់ជាពិសេសលើដំណើរបាតុភូតធម្មជាតិ<br>គ) កាត់បន្ថយអត្រាមរណៈនៃស៊ុត កូនញាស់ និងមេអណ្តើកពីការគំរាមកំហែងនៃសត្វសាហាវ និងពីសត្វចិញ្ចឹម | | |

## គោលបំណង២. ការពារ អភិរក្ស និងស្តារទីជំរកអណ្តើកសមុទ្រ

| កម្មវិធី | សកម្មភាព | អាទិភាព | ស្ថានភាពនៃការអនុវត្តន៍ |
|---|---|---|---|
| 2.1 កំនត់វិធានការណ៍ចាំបាច់ ដើម្បីការពារ និងអភិរក្សទីជំរកអណ្តើកសមុទ្រ | ក) ធ្វើអត្តសញ្ញាណតំបន់ដែលមានទីជំរកសំខាន់ដូចជាផ្លូវអណ្តើកឆ្លងកាត់ ឆ្នេរកន្លែងអណ្តើកពង កន្លែងអណ្តើកស្នាក់នៅចន្លោះពេលវាពង និងកន្លែងរកចំនី<br>ខ) កំនត់ និងគ្រប់គ្រងតំបន់ការពារ/អភិរក្ស ដែនបំរុងទុក ឬដែនមិនឱ្យមនុស្សឆ្លងកាត់ជាបណ្តោះអាសន្ននៅក្នុងតំបន់ដែលមានទីជំរកសំខាន់ ឬចាត់វិធានការណ៍ផ្សេងទៀត (ឧ. កែប្រែឧបករណ៍នេសាទ កំហិតចរាចរនៃនាវា) ដើម្បីលប់បំបាត់ការគំរាមកំហែងពីតំបន់នោះ<br>គ) បង្កើតការលើកទឹកចិត្តឱ្យមានការការពារគ្រប់គ្រាន់នៅតាមតំបន់ដែលមានទីជំរកសំខាន់ៗក្រៅតំបន់ការពារធម្មជាតិ<br>ឃ) ធ្វើការវាយតំលៃផលប៉ះពាល់បរិស្ថានចំពោះសកម្មភាពអភិវឌ្ឍន៏នៅសមុទ្រ និងតំបន់ឆ្នេរ និងបណ្តាសកម្មភាពផ្សេងៗទៀត ដែលអាចជះឥទ្ធិពលដល់បណ្តាភាវៈអណ្តើក និងទីជំរករបស់វា<br>ង) គ្រប់គ្រង និងដាក់កំហិតលើការប្រើប្រាស់ឆ្នេរសមុទ្រ និងឆ្នេរខ្សាច់ នៅក្នុងប្រទេសរៀងៗខ្លួន ឧ. កំនត់ទីតាំង និងគំរូអាគារ ការប្រើប្រាស់ភ្លើងបំភ្លឺសិប្បនិម្មិត និងចរាចរយានយន្តឆ្លងកាត់តំបន់អណ្តើកពង<br>ច) តាមដាន និងជំរុញកិច្ចការពារគុណភាពទឹកពីការបំពុលដែលមានប្រភពពីសមុទ្រ និងពីដីគោក រួមទាំងកំទេចកំទីពីសមុទ្រ ដែលអាចបង្កផលប៉ះពាល់ដល់អណ្តើកសមុទ្រ<br>ឆ) ពង្រឹងការហាមឃាត់ក្នុងការប្រើប្រាស់សារធាតុគីមីពុល និងគ្រឿងផ្ទុះក្នុងការធ្វើអាជីវកម្មធនធានសមុទ្រ | | |
| 2.2 ស្តារទីជំរកអណ្តើសមុទ្រ ដែលខូចខាត | ក) ក្នុងករណីសមស្រប ដាំព្រៃឡើងវិញនៅតាមឆ្នេរខ្សាច់តាមកន្លែងអណ្តើកពង ដោយប្រើប្រាស់ប្រភេទរុក្ខជាតិក្នុងស្រុក ដើម្បីជាឧបសគ្គចំពោះការអភិវឌ្ឍន៏ក្នុងតំបន់ឆ្នេរ និងជាការស្តាររបបសីតុណ្ហភាពសមស្របនៅតាមឆ្នេរ<br>ខ) សំអាតកំទិចកំទីដែលជាឧបសគ្គដល់អណ្តើកពង និងកូនទើបញាស់<br>គ) បង្កើនដំណុះឡើងវិញនៃផ្កាថ្មដែលរិចរិល<br>ឃ) បង្កើនដំណុះឡើងវិញនៃព្រៃកោងកាង និងស្មៅសមុទ្រដែលរិចរិល | | |

**គោលបំណង ៣. លើកស្ទួយការយល់ដឹងអំពីអេកូឡូស៊ីអណ្តើកសមុទ្រ និងបណ្តាភាវៈអណ្តើកសមុទ្រតាមរយៈការសិក្សាស្រាវជ្រាវ តាមដាន និងផ្លាស់ប្តូរព័ត៌មាន**

| កម្មវិធី | សកម្មភាព | អទិភាព | ស្ថានភាពនៃការអនុវត្តន៍ |
|---|---|---|---|
| 3.1 សិក្សាអំពីអណ្តើកសមុទ្រ និងទីជំរករបស់វា ក្នុងគោលដៅអភិរក្ស និងគ្រប់គ្រង | ក) ធ្វើការសិក្សាគោល ឬប្រមូលព័ត៌មានដែលមានស្រាប់អំពីបណ្តាភាវៈអណ្តើកសមុទ្រ និងទីជំរករបស់វា<br>ខ) ផ្តួចផ្តើម និង/ឬបន្តធ្វើការសិក្សាតាមដានរយៈពេលវែង សំរាប់បណ្តាភាវៈនៃប្រភេទអណ្តើកដែលមានអាទិភាព ដើម្បីវាយតំលៃស្ថានភាពអភិរក្ស<br>គ) កំនត់អត្តសណ្ឋាណសេនេទិកនៃបណ្តាភាវៈអណ្តើកសមុទ្រ<br>ឃ) ធ្វើអត្តសញ្ញាណផ្លូវអណ្តើកឆ្លងកាត់ តាមរយៈការដាក់សញ្ញាសំគាល់លើខ្លួនអណ្តើក ការសិក្សាសេនេទិក និង/ឬការតាមដានដោយប្រើផ្កាយរណប<br>ង) សិក្សាឪណាមិកបណ្តាភាវៈនៃអណ្តើកសមុទ្រ និងអត្រាគង់វង់<br>ច) ស្រាវជ្រាវអំពីរោគសាស្ត្រ និងភាពញឹកញាប់នៃជំងឺអណ្តើកសមុទ្រ<br>ឆ) ជំរុញការប្រើប្រាស់ចំណេះដឹងតាមបែបបុរាណអំពីអេកូឡូស៊ីនៅក្នុងការសិក្សាស្រាវជ្រាវ<br>ជ) ពិនិត្យឡើងវិញជាទៀងទាត់ និងវាយតំលៃសកម្មភាពនៃការស្រាវជ្រាវ និងការតាមដាន | | |
| 3.2 សិក្សាស្រាវជ្រាវ និងតាមដានរួមគ្នា | ក) ធ្វើអត្តសញ្ញាណ និងបញ្ចូលតំរូវការលើផ្នែកស្រាវជ្រាវ និងតាមដាននៅក្នុងផែនការសកម្មភាពប្រចាំតំបន់ និងអនុតំបន់<br>ខ) ធ្វើការសិក្សា និងតាមដានរួមគ្នាលើអត្តសញ្ញាណសេនេទិក ស្ថានភាពអភិរក្ស ការផ្លាស់ទី និងទិដ្ឋភាពជីវសាស្ត្រ និងអេកូឡូស៊ីនានានៃអណ្តើកសមុទ្រ | | |
| 3.3 វិភាគទិន្នន័យដើម្បីរួមចំណែកកាត់បន្ថយការកំរាមកំហែង និងដើម្បីវាយតំលៃ និងកែលំអរគោលនយោបាយអភិរក្ស | ក) ចាត់ជាអទិភាពនូវបណ្តាភាវៈដែលត្រូវការសកម្មភាពអភិរក្ស<br>ខ) ធ្វើអត្តសញ្ញាណនិន្នាការបណ្តាភាវៈ<br>គ) ប្រើប្រាស់លទ្ធផលពីការស្រាវជ្រាវដើម្បីកែលំអរការគ្រប់គ្រង កាត់បន្ថយការគំរាមកំហែង និងវាយតំលៃប្រសិទ្ធិភាពនៃសកម្មភាពអភិរក្ស (ឧ. សកម្មភាពគ្រប់គ្រងអាងភ្ញាស់ ការបាត់បង់ទីជំរក ។ល។) | | |
| 3.4 ការផ្លាស់ប្តូរព័ត៌មាន | ក) ធ្វើបមាណីយកម្មវិធី និងក៏រិតនៃការប្រមូលទិន្នន័យ ហើយបន្សាំ ឬបង្កើតនីតិវិធីសំរាប់ការសិក្សាតាមដានឆ្នេរជាកន្លែងអណ្តើកពង សិក្សាពីកន្លែងរកចំណី ការយកគំរូសេនេទិក និងប្រមូលទិន្នន័យអំពីអត្រាមរណៈ<br>ខ) កំនត់វិធីសាស្ត្រសមស្របបំផុតសំរាប់ផ្សព្វផ្សាយព័ត៌មាន<br>គ) ផ្លាស់ប្តូរជាទៀងទាត់នូវព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស និងជំនាញក្នុងចំណោមប្រជាជាតិ ស្ថាប័នវិទ្យាសាស្ត្រ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើម្បីបង្កើត និងអនុវត្តវិធីប្រសើរបំផុតសំរាប់អភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា<br>ឃ) ផ្សព្វផ្សាយចំណេះដឹងបុរាណអំពីអណ្តើកសមុទ្រ និងទីជំរករបស់វាសំរាប់បំរើការងារអភិរក្ស និងគ្រប់គ្រង<br>ង) ប្រមូលទិន្នន័យអំពីបណ្តាភាវៈអណ្តើកសមុទ្រដែលទទួលចំណាប់អារម្មណ៍នៅក្នុងតំបន់ឱ្យបានទៀងទាត់ | | |

**គោលបំណង៤. បង្កើនការយល់ដឹងសាធារណៈអំពីការគំរាមកំហែងចំពោះអណ្តើកសមុទ្រ និងទីជំរករបស់វា និងបង្កើនការចូលរួមរបស់សាធារណៈជនក្នុងការអភិរក្ស**

| កម្មវិធី | សកម្មភាព | អទិភាព | ស្ថានភាពនៃការអនុវត្តន៍ |
|---|---|---|---|
| 4.1 បង្កើតកម្មវិធីអប់រំសាធារណៈ កម្មវិធីបង្កើនការយល់ដឹង និងពិតមាន | ក) ប្រមូល រៀបចំ និងចែកចាយឯកសារអប់រំ<br>ខ) បង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលសហគមន៍ / ពតិមាន<br>គ) បង្កើត និងអនុវត្តកម្មវិធីផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយពិតមាន<br>ឃ) បង្កើត និងអនុវត្តកម្មវិធីអប់រំ និងការយល់ដឹងសំរាប់ក្រុមគោលដៅ (ឧ. អ្នករៀបចំគោលនយោបាយ គ្រូបង្រៀន សាលារៀន សហគមន៍នេសាទ ប្រព័ន្ធផ្សព្វផ្សាយពិតមាន)<br>ង) លើកទឹកចិត្តឱ្យមានការបញ្ចូលមុខវិជ្ជាអំពីជីវសាស្ត្រអណ្តើកសមុទ្រ និងបញ្ហានៃការអភិរក្សទៅក្នុងកម្មវិធីសំរាប់សាលារៀន<br>ច) រៀបចំព្រឹត្តិការពិសេសទាក់ទងនឹងការអភិរក្ស និងលក្ខណៈជីវសាស្ត្រនៃអណ្តើកសមុទ្រ (ឧ. ទិវាអណ្តើក ឆ្នាំនៃអណ្តើក សន្និសិទ តាមរកអណ្តើក) | | |
| 4.2 បង្កើតឱកាសក្នុងមុខរបរសំរាប់សហគមន៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តឱ្យពួកគេមានការចូលរួមយ៉ាងសកម្មក្នុងកិច្ចការអភិរក្ស | ធ្វើអត្តសញ្ញាណ និងសំរួលឱ្យមានជំរើសផ្សេងក្នុងមុខរបរ (រួមទាំងសកម្មភាពរកចំណូល) ដែលមិនបង្កការគំរាមកំហែងដល់អណ្តើកសមុទ្រ និងទីជំរករបស់វា ដោយពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ | | |
| 4.3 ជំរុញការចូលរួមរបស់សាធារណៈជន | ក) ឱ្យភាគីពាក់ព័ន្ធ ពិសេសសហគមន៍មូលដ្ឋានចូលរួម ក្នុងការធ្វើផែនការ និងអនុវត្តវិធានការណ៍អភិរក្ស និងគ្រប់គ្រង<br>ខ) លើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នឯកជន និងសហគមន៍ទូទៅ (ឧ. និស្សិត អ្នកស្ម័គ្រចិត្ត សហគមន៍នេសាទ សហមន៍មូលដ្ឋាន) ក្នុងការងារស្រាវជ្រាវ និងអភិរក្ស<br>គ) ក្នុងករណីសមស្រប អនុវត្តវិធានការណ៍លើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណៈជន (ឧ. ការផ្តល់អាវយឺតជាថ្នូរនឹងការប្រគល់ផ្លាកសំគាល់ ការលើកសរសើរជាសាធារណៈ ប័ណ្ណសរសើរ) | | |

## គោលបំណង ៥. លើកស្ទួយកិច្ចសហការក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ

| | កម្មវិធី | សកម្មភាព | អាទិភាព | ស្ថានភាព នៃការអនុវត្តន៍ |
|---|---|---|---|---|
| 5.1 | សហប្រតិបត្តិការជាមួយ និងជួយបណ្តារដ្ឋជាហត្ថលេខី និងមិនមែនជាហត្ថលេខី ដើម្បីដាក់កំហិត និងចែករំលែកព័ត៌មានអំពីពាណិជ្ជកម្ម ដើម្បីប្រឆាំងពាណិជ្ជកម្មខុសច្បាប់ និងដើម្បីសហការពង្រឹងសកម្មភាពពាក់ព័ន្ធនឹងផលិតផលពីអណ្តើកសមុទ្រ | ក) លើកទឹកចិត្តបណ្តារដ្ឋជាហត្ថលេខីដែលមិនទាន់បានក្លាយជាសមាជិកនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិប្រភេទសត្វ និងរុក្ខជាតិកំពុងប្រឈមគ្រោះថ្នាក់ <u>(CITES)</u> ឱ្យចាត់ចែងដាក់ពាក្យសុំចូលជាសមាជិកនៃអនុសញ្ញានេះ<br>ខ) ពិនិត្យពីកាតព្វកិច្ចរបស់ជាតិទាក់ទងនឹងការគោរពតាមអនុសញ្ញា <u>CITES</u> ពាក់ព័ន្ធនឹងពាណិជ្ជកម្មអណ្តើកសមុទ្រ ស៊ុតរបស់វា បំណែកនៃសារពាង្គកាយ ឬផលិតផលពីអណ្តើក<br>គ) សំរបសំរួលឱ្យមានការបំពេញកាតព្វកិច្ចតាមអនុសញ្ញា <u>CITES</u> កាន់តែប្រសើរឡើងតាមរយៈការបណ្តុះបណ្តាលអាជ្ញាធរពាក់ព័ន្ធ ដោយសហការជាមួយបណ្តារដ្ឋផ្សេងទៀតជាហត្ថលេខី លេខាធិការដ្ឋានអនុសញ្ញា<u>CITES</u> និងអង្គការពាក់ព័ន្ធដទៃទៀត<br>ឃ) ធ្វើអត្តសញ្ញាណផ្លូវពាណិជ្ជកម្មអន្តរជាតិដោយខុសច្បាប់ តាមរយៈការសិក្សាតាមដាន និងសុំកិច្ចសហការក្នុងការចាត់វិធានការណ៍រាំងស្កាត់ ត្រួតពិនិត្យ និងក្នុងករណីអាចធ្វើបាន ត្រូវលប់បំបាត់ពាណិជ្ជកម្មខុសច្បាប់<br>ង) ផ្លាស់ប្តូរ និងពិភាក្សាព័ត៌មានស្តីពីកាតព្វកិច្ច និងបញ្ហាពាណិជ្ជកម្មជាទៀងទាត់ ដូចជាតាមរយៈរបាយការណ៍ប្រចាំឆ្នាំទៅលេខាធិការដ្ឋានអនុសារណៈនេះ និងនៅក្នុងសម័យប្រជុំនៃបណ្តារដ្ឋជាហត្ថលេខី<br>ច) ធ្វើអត្តសញ្ញាណ រាំងស្កាត់ ត្រួតពិនិត្យ និងក្នុងករណីអាចធ្វើបានលប់បំបាត់ពាណិជ្ជកម្មខុសច្បាប់នៅក្នុងប្រទេស តាមរយៈការសិក្សាតាមដានការអនុវត្តន៍ច្បាប់ ការធ្វើអត្តសញ្ញាណចំនុចខ្វះចន្លោះនៅក្នុងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងប្រទេសនិមួយៗ និងបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ | | |
| 5.2 | ជួយរដ្ឋជាហត្ថលេខី និងមិនមែនជាហត្ថលេខីទៅតាមការស្នើសុំ ដើម្បីបង្កើត និងអនុវត្តផែនការសកម្មភាពជាតិ ផែនការប្រចាំអនុតំបន់ និងតំបន់សំរាប់អភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ និងទីជំរករបស់វា | ក) រៀបចំបណ្តាវិធានការគ្រប់គ្រងជាគន្លឹះដែលអាចប្រើប្រាស់ជាមូលដ្ឋានសំរាប់កសាងផែនការសកម្មភាព តាមរយៈការពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ<br>ខ) ធ្វើអត្តសញ្ញាណផែនការសកម្មភាពដែលអាចប្រើប្រាស់ជាគំរូ<br>គ) ធ្វើអត្តសញ្ញាណបញ្ហាគ្រប់គ្រងជាក់លាក់ក្នុងមូលដ្ឋានដែលត្រូវការឱ្យមានកិច្ចសហការរវាងរដ្ឋនានា ដើម្បីឱ្យការអភិរក្សនិងគ្រប់គ្រងទទួលជោគជ័យ<br>ឃ) កែសំរួលឡើងវិញនូវផែនការសកម្មភាពជាទៀងទាត់ ដើម្បីបញ្ចូលនូវរាល់ស្ថានភាពរីកចំរើននៃទេពកោសល្យ និងចំណេះដឹង ពាក់ព័ន្ធនឹងការអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ | | |
| 5.3 | ពង្រឹងយន្តការសំរាប់សហការ និងជំរុញការផ្លាស់ប្តូរព័ត៌មាន | ក) ធ្វើអត្តសញ្ញាណ និងពង្រឹងយន្តការដែលមានសំរាប់ពង្រឹងកិច្ចសហប្រតិបត្តិការនៅកំរិតអនុតំបន់<br>ខ) បង្កើតព្រឹត្តបត្តិ ឬព័ត៌មានតាមប្រព័ន្ធអ៊ិនធឺណែតដើម្បីសំរួលក្នុងទំនាក់ទំនង និងផ្លាស់ប្តូរព័ត៌មាន<br>គ) បង្កើតមូលដ្ឋានព័ត៌មានតាមប្រព័ន្ធអ៊ិនធឺណែតសំរាប់ការអភិរក្សអណ្តើកសមុទ្រ (រួមទាំងទិន្នន័យស្តីពីបណ្តាភារៈ ការធ្វើសំបុក ការផ្លាស់ទី | | |

| | | | |
|---|---|---|---|
| | បណ្តាគំរោងកំពុងអនុវត្ត)<br>ឃ) រៀបចំសៀវភៅរាយនាមអ្នកជំនាញ និងអង្គការពាក់ព័ន្ធនឹងការងារអភិរក្សអណ្តើកសមុទ្រ<br>ង) បង្កើតបណ្តាញការងារសំរាប់ការគ្រប់គ្រងរួមនៃចំណែកបណ្តាភារៈ នៅក្នុង ឬឆ្លងកាត់អនុតំបន់ និងក្នុងករណីសមស្រប ចាត់ចែងឱ្យមានការគ្រប់គ្រងរួមគ្នា<br>ច) ក្នុងករណីអាចធ្វើបាន សហការបង្កើតតំបន់ការពារធម្មជាតិសមុទ្រនៅតាមព្រំប្រទល់ប្រទេស ដោយផ្អែកលើទស្សនៈអេកូឡូស៊ី ជាជាងនយោបាយ<br>ឆ) បង្កើតទំរង់រាយការណ៍ និងផ្លាស់ប្តូរពិតមាន (តាមរយៈលេខាធិការដ្ឋានរបស់អនុសារណៈនេះ និងក្នុងចំណោមរដ្ឋជាហត្ថលេខី) ស្តីពីស្ថានភាពនៃការអភិរក្សអណ្តើកសមុទ្រ នៅថ្នាក់ជាតិ<br>ជ) លើកទឹកចិត្តបណ្តារដ្ឋជាហត្ថលេខីនៃអនុសារណៈនេះ ដែលនៅពុំទាន់បានសុំចូលជាសមាជិកនៃអនុសញ្ញាស្តីពីការអភិរក្សប្រភេតផ្លាស់ទីតាមរដូវ<br>ឈ) លើកទឹកចិត្តបណ្តារដ្ឋជាហត្ថលេខីឱ្យចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេសាទពិភពលោក ដូចជា កិច្ចព្រមព្រៀងសហប្រជាជាតិស្តីពីសន្និធិមច្ឆជាតិ (1995) និងកិច្ចព្រមព្រៀងអនុវត្តនៃកម្មវិធីស្បៀង និងកសិកម្មសហប្រជាជាតិ (1993) និងអនុវត្តបទបញ្ជារបស់កម្មវិធីស្បៀង និងកសិកម្មសហប្រជាជាតិសំរាប់ការនេសាទប្រកបដោយការទទួលខុសត្រូវ (1995)<br>ញ) បង្កើតទំនាក់ទំនងជាមួយអង្គភាពនេសាទក្នុងតំបន់ ដើម្បីទទួលយកទិន្នន័យស្តីពីការនេសាទអណ្តើកដោយចៃដន្យ និងលើកទឹកចិត្តឱ្យពួកគេបន្សាំនឹងវិធានការណ៍អភិរក្សអណ្តើកសមុទ្រ ក្នុងដែនសមុទ្រសេដ្ឋកិច្ចផ្តាច់មុខ និងនៅសមុទ្រអន្តរជាតិ | | |
| 5.4 កសាងសមត្ថភាព ដើម្បីពង្រឹងវិធាន-ការណ៍អភិរក្ស | ក) ធ្វើអត្តសញ្ញាណតំរូវការសំរាប់ការកសាងសមត្ថភាពធនធានមនុស្ស ចំណេះដឹង និងសម្ភារ<br>ខ) បណ្តុះបណ្តាល (ឧ. តាមរយៈសិក្ខាសាលា) អំពីបច្ចេកទេសអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រដល់ស្ថាប័នពាក់ព័ន្ធ បុគ្គល និងសហគមន៍មូលដ្ឋាន<br>គ) សំរបសំរួលកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលា<br>ឃ) បង្កើតភាពជាដៃគូជាមួយសកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ អង្គភាពបណ្តុះបណ្តាល និងបណ្តាអង្គការពាក់ព័ន្ធផ្សេងទៀត | | |
| 5.5 ពង្រឹង និងកែលំអរការអនុវត្តន៍ច្បាប់អភិរក្ស | ក) កែលំអរឡើងវិញគោលនយោបាយ និងច្បាប់ក្នុងប្រទេស ដើម្បីបំពេញចំនុចខ្វះចន្លោះ ឬឧបសគ្គក្នុងការអភិរក្សអណ្តើកសមុទ្រ<br>ខ) សហការក្នុងការពង្រឹងការអនុវត្តន៍ច្បាប់ ដើម្បីធានាការអនុវត្តន៍ច្បាប់មានភាពស៊ីសង្វាក់គ្នានៅទូទាំង និងឆ្លងកាត់ព្រំប្រទល់យុត្តាធិការ (រួមទាំងតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី/ពហុភាគី និងការចែករំលែកទ្រព្យសម្បត្តិខាងបញ្ញា) | | |

## គោលបំណង ៦. ជំរុញការអនុវត្តន៍អនុសារណៈនេះ រួមទាំងផែនការអភិរក្ស និងគ្រប់គ្រង

| កម្មវិធី | សកម្មភាព | អទិភាព | ស្ថានភាព នៃការអនុវត្តន៍ |
|---|---|---|---|
| 6.1 ពង្រីកសមាជិកភាពក្នុងអនុសារណៈនេះ និងធានាបន្តសកម្មភាពនៃអនុសារណៈនេះ | ក) លើកទឹកចិត្តបណ្តារដ្ឋដែលមិនមែនជាហត្ថលេខីឱ្យចុះហត្ថលេខាលើអនុសារណៈនេះ<br>ខ) រៀបចំសិក្ខាសាលាអនុតំបន់ឱ្យមានការចូលរួមពីសំណាក់រដ្ឋមិនមែនជាហត្ថលេខី ដើម្បីបង្កើនការយល់ដឹងពីអនុសារណៈនេះ<br>គ) នៅក្នុងសម័យប្រជុំលើកទីមួយនៃរដ្ឋជាហត្ថលេខី ពិចារណារៀបចំកាលបរិច្ឆេទសំរាប់ការធ្វើវិសោធនកម្មអនុសារណៈនេះ ដើម្បីឱ្យក្លាយជាឧបករណ៍អាចរក្សាបានសុពលភាពខាងផ្នែកច្បាប់ | | |
| លើកស្ទួយតួនាទីនៃលេខាធិការដ្ឋាន និងគណៈកម្មាធិការផ្តល់យោបល់ នៃអនុសារណៈនេះក្នុងការធានាបំពេញឱ្យបានតាមគោលបំណងនៃផែនការអភិរក្ស និងគ្រប់គ្រងនេះ | ក) ស្វែងរកប្រភពហិរញ្ញវត្ថុអាចទុកចិត្តបានសំរាប់ទ្រទ្រង់លេខាធិការដ្ឋាននៃអនុសារណៈនេះ<br>ខ) នៅក្នុងសម័យប្រជុំលើកទីមួយនៃរដ្ឋជាហត្ថលេខី តែងតាំងសមាជិកនៃគណៈកម្មាធិការផ្តល់យោបល់<br>គ) បង្កើតរបៀបទំនាក់ទំនងពិតមានរវាងលេខាធិការដ្ឋានអនុសារណៈនេះ និងគណៈកម្មាធិការផ្តល់យោបល់ ដើម្បីសំរួលការផ្តល់យោបល់ដល់រដ្ឋជាហត្ថលេខី | | |
| 6.3 ស្វែងរកធនធានដើម្បីទ្រទ្រង់ការអនុវត្តន៍អនុសារណៈនេះ | ក) កំនត់អទិភាពសកម្មភាពអភិរក្ស និងគ្រប់គ្រង សំរាប់ផ្តល់ហិរញ្ញវត្ថុ<br>ខ) ស្វែងរកជំរើសហិរញ្ញវត្ថុជាមួយរដ្ឋាភិបាល និងបណ្តាស្ថាប័នផ្តល់ជំនួយនានាដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហភាពអឺរ៉ុប កម្មវិធីបរិស្ថានពិភពលោក មូលនិធិបរិស្ថានពិភពលោក ។ល។<br>គ) ស្នើសុំឱ្យមានការផ្តល់ហិរញ្ញវត្ថុ និងវិភាគទាននានាពីឧស្សាហកម្មដែលបង្កផលប៉ះពាល់ដល់អណ្តើកសមុទ្រ និងទីជំរករបស់វា (ឧ. ឧស្សាហកម្មនេសាទ ទេសចរណ៍ ឧស្សាហកម្មប្រេងកាត ទ្រព្យអចលនះ)<br>ឃ) ស្រាវជ្រាវការប្រើប្រាស់វិធានការណ៍សេដ្ឋកិច្ចសំរាប់អភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា<br>ង) ទាក់ទងស្ថាប័នឯកជន ស្ថាប័នមូលនិធិ និងអង្គការក្រៅរដ្ឋាភិបាល ដែលអាចមានចំណាប់អារម្មណ៍ក្នុងការផ្តល់ហិរញ្ញវត្ថុសំរាប់សកម្មភាពក្នុងបណ្តាប្រទេសណាមួយ ដើម្បីសំរួលដល់ការបង្កើតមូលនិធិអំណោយទ្រង់ទ្រាយតូច<br>ច) សន្សំមូលនិធិសំរាប់សកម្មភាពអភិរក្ស និងគ្រប់គ្រង តាមរយៈសកម្មភាពទេសចរណ៍ដែលមានការគ្រប់គ្រងល្អ និងវិធានការណ៍ទ្រទ្រង់ដោយខ្លួនឯងផ្សេងទៀត (ដោយធានាការផ្តល់ប្រយោជន៏ដល់សហគមន៍មូលដ្ឋាន)<br>ឆ) ធ្វើឱ្យមានភាពចុះសំរុងគ្នា (ទាក់ទងនឹងការស្វែងរកមូលនិធិ ការផ្តល់កិច្ចគាំទ្រខាងផ្នែកស្ថាប័ន ។ល។) ជាមួយលេខាធិការដ្ឋាននៃអនុសញ្ញាផ្សេងៗ ប្រចាំតំបន់/ពិភពលោក<br>ជ) ស្រាវជ្រាវរកការគាំទ្រអន្តរជាតិខាងផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្តនានា សំរាប់បណ្តារដ្ឋជាហត្ថលេខី ដែលគ្រប់គ្រងបណ្តាភាវះអណ្តើកសមុទ្រមានប្រសិទ្ធិភាព ដែលអាចរួមមាន ការហាមឃាត់ទាំងស្រុងនូវការប្រមូលផលដោយផ្ទាល់ (ចាប់ ឬសំលាប់) | | |
| 6.4 កែលំអរការសំរបសំរួលក្នុងចំណោមស្ថាប័នរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលក្នុងកិច្ចការអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា | ក) កែសំរួលតួនាទី និងការទទួលខុសត្រូវនៃស្ថាប័នរដ្ឋាភិបាល ពាក់ព័ន្ធនឹងការអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ និងទីជំរករបស់វា<br>ខ) តែងតាំងស្ថាប័ននាំមុខក្នុងប្រទេសសំរាប់ទទួលខុសត្រូវសំរបសំរួលគោលនយោបាយអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ<br>គ) លើកទឹកចិត្តឱ្យមានកិច្ចសហការនៅក្នុង និងរវាងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នក្រៅរដ្ឋាភិបាល រួមទាំងតាមរយៈការបង្កើត និង/ឬពង្រឹងបណ្តាញការងារនៅថ្នាក់ជាតិ | | |